# នគរកាយ

## គតិធម៌ ធៀប គតិលោក

រៀបរៀងដោយ

ឧត្តមប្រឹជា **ចាប-ពិន** និពន្ធបណ្ឌិត

ចម្លងដោយៈ

លេខ១៣១អឹម វិថីទេសភូមិន្ទ រាជធានីភ្នំពេញ

ព.ស២៥៤១ គ.ស១៩៩៨

# ឯករកាយ

គតិធម៌ ធៀប គតិលោក

រៀបរៀងដោយ

ឧត្តមប្រឹជា ចាប-ពិន និពន្ធបណ្ឌិត

អតីតអ្នកនិពន្ធតែងសេចក្តី និង
អធិបតីក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ
នៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ

រក្សាសិទ្ធិ

# លំនាំដើម

៧២

( លើកទី ១)

រឿង នគរកាយ នេះ ជាគតិធម៌ ប្រៀប គតិលោក ដោយយកចិត្តចេតសិកជានាមធម៌ ( ធម្មាធិដ្ឋាន ) មកតែងជារូបធម៌ ( បុគ្គលាធិដ្ឋាន ) សន្មតជាស្រុក នគរ ស្ដេច មន្ត្រី អាមាត្យ យោធាទាហាន ឲ្យមានសេចក្ដីទាក់ទងគ្នា ជារឿងនិទានប្រលោម ពីធ្វើធម៌ជ្រៅឲ្យរាក់ ធម៌ក្រឲ្យងាយ ។

រឿងនេះ ខ្ញុំរៀបរៀងតាមលំអានសាស្ត្រាស្លឹករឹតបុរាណ ដែលឥតមាននាមលោកអ្នកតែង មានសេចក្ដីវែង ៗ ឲ្យជានិទានខ្លី ៗ ដោយសេចក្ដីអនុគ្រោះដល់កុលបុត្រអ្នកសិក្សា សូម្បីជាកុមារក៏ឲ្យអានមើលស្ដាប់ឆាប់ចូលចិត្តសេចក្ដីបាន ។

ពុទ្ធសាសនិកជនអ្នកបុណ្យអ្នកទាន គួរតែមានរឿងនគរកាយនេះទុកជាអារ្យទ្រព្យរបស់ខ្លួន សំរាប់អានមើលផ្ទាល់ខ្លួន ឬ ឲ្យគេអានឲ្យស្ដាប់ ឬ ក៏និមន្តបព្វជិតទេសនា ក្នុងថ្ងៃសីល ឬ ពេលទំនេរ ឬ ក៏វេលាជរាពាធ ។

បើតាមការបង្ហូរនាក់ស្កឹករឹត សំរាប់និពន្ធអ្នកដឹក ទេសនាក្នុងទីប្រជុំបុណ្យទាន ក៏រឹតតែជាប់ប្រសើរណាស់ ជាការតអាយុព្រះពុទ្ធសាសនា ញុំាងបសាទ - សង្វេគ សុចរិត ជាហេតុនៃបុណ្យកុសលដែលអាចផ្តល់សេចក្តីសុខ - ចំរើនក្នុងលោកនេះ លោកខាងមុខ និង ញុំាងបច្ច័យនៃព្រះនិព្វាន ឱ្យកើតមានដល់ពុទ្ធបរិស័ទក្នុងអនាគតជាអនេកតទៅ ។

សូមសិរីសួស្តីកើតមានដល់លោក-អ្នកអាន និង
អ្នកស្តាប់ទាំងឡាយ

ថ្ងៃទី១ មករា ព. ស ២៤៩៥ គ. ស ១៩៥២

ស ចាប ពិន

រូបនេះ ជារូបស្លាឡិតគិត ពិចារណា អំពីសង្ខារប្រែប្រួល




អនិច្ចា = សង្ខារ មិនទៀងត្រង់មុខ . ទុក្ខា = មានទុក្ខច្រើនពន់ប្រមាណ
អនត្តា = សូន្យសោះ មិនមែនខ្លួនប្រាណ . និព្វាន = ទើបបាន បរមសុខពិត ។

# នគរកាយ

## គតិធម៌ ធៀប គតិលោក

ॐॐॐ

### នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យ, ហើយសូមសំដែងនូវអត្ថកថា ជាគតិធម៌ ធៀប គតិលោក ដូចតទៅនេះ :

ឯកោ រាជា ចិត្តំ នាម នគរកាយេ រជ្ជំ ការេសិ ។ តស្ស អគ្គមហេសី អវិជ្ជា ទេវី នាម, បិតា មោហោ នាម, មាតា លោភទេវី នាម ។

*សាធុសប្បុរសទាំងឡាយ !*

*ក្នុងអតីតកាល, មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទ* ចិត្តរាជ *ជាបរមស្រីក្រុងរាជសម្បត្តិ ក្នុងព្រះនគរមួយឈ្មោះ* នគរកាយ *។ ព្រះរាជាអង្គនោះមានព្រះអគ្គមហេសីទ្រង់ព្រះនាមព្រះនាង* អវិជ្ជាទេវី *ជាទីគាប់ព្រះទ័យ*

ជាងព្រះស្មុំទាំងពួង, ព្រះបិតាទ្រង់ព្រះនាមព្រះពាច មោហរាជ ព្រះមាតា ទ្រង់ព្រះនាមព្រះនាង លោភទេវី ។

ជនកាយនោះមានទ្វារ ៩ គឺ :

ចក្ខុទ្វារ ( ទ្វារភ្នែក ) ២ .

សោតទ្វារ ( ទ្វារត្រចៀក ) ២ .

ឃានទ្វារ ( ទ្វារច្រមុះ ) ២ .

ជីវ្ហាទ្វារ ( ទ្វារមាត់ ) ១ .

បស្សាវទ្វារ ( ទ្វារតូច ) ១ .

ឧច្ចារទ្វារ ( ទ្វារធំ ) ១ ។

មានប្រាង្គប្រាសាទ ៥ គឺ :

១_ ចក្ខុប្រាសាទ ( ១ ) ជាព្រះទីនាំងសំរាប់ព្រះមហាក្សត្រទ្រង់ទតល្បែងរាំទាំងពួង

១_ ត្រង់បទនេះ ក្នុងអភិធម្មសង្គហៈថា ចក្ខុបសាទ ។ បាន ជាក្នុងទីនេះថា ចក្ខុប្រាសាទ ព្រោះផ្ទាតពិធមិ មៀប តពិ លោក។

២_ សោតប្រាសាទ ជាព្រះទីនាំងសំរាប់ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់សូរស័ព្ទតូរ្យតន្ត្រីទាំងពួង

៣_ ឃានប្រាសាទ ជាព្រះទីនាំងសំរាប់ព្រះមហាក្សត្រទ្រង់ព្រះសុគន្ធរស

៤_ ជីវ្ហាប្រាសាទ ជាព្រះទីនាំងសំរាប់ព្រះមហាក្សត្រទ្រង់សោយព្រះសុង្ហារភោជនាហារដ៏មានឱជារស

៥_ កាយប្រាសាទ ជាព្រះទីនាំងសំរាប់ព្រះមហាក្សត្រទ្រង់គ្រឿងអលង្ការទាំងពួង ទាំងគ្រឿងបញ្ចកកុធភណ្ឌ ជាគ្រឿងសំរាប់រាជ្យជាដើម ។

ព្រះបាទចក្ររាជ ព្រះអង្គមានមហាតល្លិក ៧ នាក់ ដែលទ្រង់តាំងក្នុងឋានន្តរស័ក្តិទីហ្លួង មានមុខងារផ្សេងៗ គ្នា សម្រាប់ជារាជបម្រើតាមពេលដែលទ្រង់ត្រូវការគឺ

១_ ហ្លួងផៃស្រា (១) ជាអ្នកចាប់កាន់ព្រះអង្គ.

២_ ហ្លួងសញ្ញា ជាអ្នកចាំសំគាល់កិច្ចការទាំងពួងព្រះរាជាដែលទ្រង់ប្រើឱ្យកត់សំគាល់ ;

---

១_ ចេតសិកទាំង ៧ នេះ ក្នុងអភិធម្មសង្គហៈ ហៅថាសព្វសាធារណចេតសិក ។

៣_ ហ្គីនវេទនា ជាអ្នកណែនាំព្រះមហាក្សត្រឱ្យសោយអារម្មណ៍ផ្សេង ៗ មានសុខជាដើម ,

៤_ ហ្គីនចេតនា ជាអ្នកចាំទទួលព្រះរាជឱង្ការក្នុងកាលដែលព្រះរាជាត្រូវការប្រើទៅកាន់ទីណា ក៏ទៅបានដោយរហ័ស

៥_ ហ្គីនឯកគ្គតា ជាអ្នកស្លូតត្រង់. ព្រះរាជាទ្រង់ទុកព្រះទ័យជឿយកពាក្យ

៦_ ហ្គីនមនសិការោ ជាអ្នកយកចិត្តទុកដាក់ក្នុងកិច្ចការផ្សេង ៗ ដែលព្រះរាជាទ្រង់ប្រើ,

៧_ ហ្គីនជីវិតិន្ទ្រិយ ជាអ្នកជួយផ្គត់ផ្គង់ព្រះជន្មព្រះរាជាឱ្យមានព្រះជីវភាព ។

ព្រះបាទចិត្តរាជ ព្រះអង្គមានបុរោហិត ៣ រូប ទ្រង់តាំងទុកក្នុងឋានន្តរស័ក្តិជារាជគ្រូ សម្រាប់ណែនាំព្រះអង្គក្នុងព្រះរាជពិធីផ្សេង ៗ តាមដែលទ្រង់ត្រូវការដ៏

១_ រាជគ្រូវិតក្កោ (១) ជាអ្នកណែនាំព្រះរាជាឱ្យត្រិះរិះក្នុងកិច្ចការផ្សេង ៗ

---

១ ចេតសិកពួកនេះ ក្នុងអភិធម្មត្ថសង្គហៈ បកិណ្ណកចេតសិក ។

២_ រាជគ្រូវិចារោ ជាអ្នកណែនាំព្រះរាជាឲ្យពិចារណានូវកិច្ចការផ្សេង ៗ

៣_ រាជគ្រូអធិមោក្ខោ (១) ជាអ្នកណែនាំព្រះរាជាឲ្យមានព្រះទ័យតាំងស៊ប់ក្នុងកិច្ចការផ្សេង ៗ ។

ព្រះធម្មចក្ករាជ ព្រះអង្គមានឥសី ៣ រូបទៀតប្រកបដោយអភិញ្ញា និងសមាបត្តិ ព្រះអង្គទ្រង់តាំងទុកក្នុងឋានគួរសក្តិជាអ្នកពន្យល់ព្រះអង្គ

១_ ព្រះបីតិ (១) ជាអ្នកពន្យល់ព្រះរាជាឲ្យបានព្រះអំណរត្រជាក់ត្រជុំស្រស់ស្រាយក្នុងអារម្មណ៍ផ្សេង ៗ

២- ព្រះឆន្ទោ ជាអ្នកពន្យល់ព្រះរាជាឲ្យមានព្រះទ័យស្រឡាញ់នូវកិច្ចការទាំងពួង

៣_ ព្រះវីរិយោ ជាអ្នកពន្យល់ព្រះរាជាឲ្យមានព្រះទ័យ

---

១ មេតសិកពួកនេះ ក្នុងអភិធម្មសង្គហៈហៅថាបកិណ្ណកចេតសិក ។

ព្យាយាមក្នុងកិច្ចការផ្សេង ៗ ។

មិនតែប៉ុណ្ណោះព្រះពាចចិត្តរាជព្រះអង្គមានព្រះភិក្ខុ ៣ រូបទ្រង់តាំងទុកសមណសក្តិជាព្រះធីតុង សម្រាប់ជួយរំលឹកព្រះអង្គគឺ

១- ព្រះអនិច្ចំ ជាអ្នករំលឹកព្រះរាជាឱ្យនឹកឃើញសេចក្តីមិនទៀងរបស់សង្ខារ

២- ព្រះទុក្ខំ ជាអ្នករំលឹកព្រះរាជាឱ្យនឹកឃើញសេចក្តីទុក្ខរបស់សង្ខារ

៣- ព្រះអនត្តា ជាអ្នករំលឹកព្រះរាជាឱ្យនឹកឃើញសេចក្តីមិនមានខ្លឹមសាររបស់សង្ខារ ។

ព្រះធីតុងទាំង ៣ រូបនេះតែងរំលឹកធម៌អាថ៌ចំពោះព្រះមហាក្សត្រ ឱ្យទ្រង់ពិចារណាឃើញតាមពិតក្នុងព្រះត្រៃលក្ខណញ្ញាណ មិនឱ្យព្រះអង្គធ្វេសប្រហែសក្នុងកុសលកម្មទាំងពួង ។

ព្រះពាចចិត្តរាជ ព្រះអង្គមានព្រះញាតិវង្ស ១៨ អង្គ ជាព្រះញាតិខាងព្រះមាតា-បិតា ជាពាលជន មានយោបល់មិនប្រពៃ ព្រះអង្គតាំងទុកក្នុងឋានន្តរសក្តិទីឃុនគ្រប់រូបគឺ :

១_ ឃុនមោហោ(១) ជាអ្នកនាំព្រះរាជាឱ្យវង្វេង

២_ ឃុនអហិរិកំ ជាអ្នកនាំព្រះរាជាមិនឱ្យខ្មាសបាប

៣_ ឃុនអនោត្តប្បំ ជាអ្នកនាំព្រះរាជាមិនឱ្យខ្លាចបាប

៤_ ឃុនឧទ្ធច្ចំ ជាអ្នកនាំព្រះរាជាឱ្យរាយមាយ

៥_ ឃុនលោភោ ជាអ្នកនាំព្រះរាជាឱ្យលោភ

៦_ ឃុនទិដ្ឋិ ជាអ្នកនាំព្រះរាជាឱ្យយល់ខុស

៧_ ឃុនមានោ. ជាអ្នកនាំព្រះរាជាឱ្យប្រកាន់ព្រះអង្គ

៨_ ឃុនទោសោ ជាអ្នកនាំព្រះរាជាឱ្យប្រទូស្តគេ

៩_ ឃុនឥស្សា ជាអ្នកនាំព្រះរាជាឱ្យច្រណែនគេ

១០_ ឃុនមច្ឆរិយំ ជាអ្នកនាំព្រះរាជាឱ្យកំណាញ់

១១_ ឃុនកុក្កុច្ចំ ជាអ្នកនាំព្រះរាជាឱ្យអន្ទះអន្ទែង.

១២_ ឃុនថីនំ ជាអ្នកនាំព្រះរាជាឱ្យរួញរា

១៣_ ឃុនមិទ្ធំ ជាអ្នកនាំព្រះរាជាឱ្យងុយងោក

១៤. ឃុនវិចិកិច្ឆា ជាអ្នកនាំព្រះរាជាឱ្យសង្ស័យ

---

(១) ចេតសិកទាំង ១៤ នេះក្នុងអភិធម្មត្ថសង្គហៈហៅថា អកុ-
សលចេតសិក

ព្រះញាតិវង្សទាំង ១៤ អង្គនេះ។ ជាអ្នកយុកព្រះទ័យ ព្រះពុទ្ធបិតុរាជយ៉ាងពិតស្និទ្ធ ព្រះអង្គតែងត្រាស់ហៅឲ្យចូលជិតជាល់បម្រើជានិច្ចកាល ពុំដែលខានពេលណាមួយឡើយ ។

ព្រះរាជាចិត្តរាជ ព្រះអង្គមានអគ្គសេនា ១៩ នាក់ ជាវរជនមានយោបល់ល្អ ព្រះអង្គតាំងទុកក្នុងឋានន្តរសក្តិ៍ទី ឧកញ៉ាគ្រប់រូបគឺ

១- ឧកញ៉ាសទ្ធា (១) ជាអ្នកនាំព្រះរាជាឲ្យជឿកម្មផល

២- ឧកញ៉ាសតិ ជាអ្នកនាំព្រះរាជាឲ្យមានព្រះស្មារតី,

៣- ឧកញ៉ាហិរិ ជាអ្នកនាំព្រះរាជាឲ្យខ្មាសបាប .

៤- ឧកញ៉ាឱត្តប្បំ ជាអ្នកនាំព្រះរាជាមិនឲ្យខ្លាចបាប,

៥- ឧកញ៉ាអលោភោ ជាអ្នកនាំព្រះរាជាមិនឲ្យលោភ,

៦- ឧកញ៉ាអទោសោ ជាអ្នកនាំព្រះរាជាមិនឲ្យប្រទូស្តគេ,

---

១ ចេតសិកទាំង ១៩ នេះក្នុងអភិធម្មត្ថសង្គហៈហៅថា សោភណសាធារណចេតសិក ។

៧_ ឧកញ្ញាតត្រមប្បស្ថតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះទ័យជាកណ្ដាល .

៨_ ឧកញ្ញាកាយបស្សទ្ធិ ជាអ្នកនាំព្រះរាជាឲ្យបានព្រះឆាយកាយរម្ងាប់

៩_ ឧកញ្ញាចិត្តបស្សទ្ធិ ជាអ្នកនាំព្រះរាជាឲ្យបានព្រះទ័យរម្ងាប់

១០_ ឧកញ្ញាកាយលហុតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះឆាយកាយស្រាល

១១_ ឧកញ្ញាកាយមុទិតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះឆាយកាយទន់ភ្លន់

១២_ ឧកញ្ញាចិត្តមុទិតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះទ័យទន់ភ្លន់

១៣_ ឧកញ្ញាកាយកម្មញ្ញតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះឆាយកាយគួរបស់ការងារ

១៤_ ឧកញ្ញាចិត្តកម្មញ្ញតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះទ័យគួរបស់ការងារ

១៦_ ឧកញ្ញាកាយបាគុញ្ញតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះនាមកាយជំនាញ

១៧_ ឧកញ្ញាចិត្តបាគុញ្ញតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះទ័យជំនាញ

១៨_ ឧកញ្ញាកាយុជុកតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះនាមកាយត្រង់

១៩_ ឧកញ្ញាចិត្តុជុកតា ជាអ្នកនាំព្រះរាជាឲ្យបានព្រះទ័យត្រង់ ។

អគ្គសេនាទាំង ១៩ នាក់នេះ ជាទីទុកព្រះទ័យព្រះរាជាចិត្តរាជ ព្រះអង្គទ្រង់តាំងទុកជាឧត្តមក្រុមប្រឹក្សា សម្រាប់ជំនុំការរាជការ ដែលទាក់ទងនឹងនគរកាយ តាមព្រះនេត្រព្រះការណ៍ព្រះអង្គ ។

ព្រះរាជាចិត្តរាជ ព្រះអង្គគ្រប់គ្រងរាជសម្បត្តិ ជាសម្បូរណ៍ ជាសិទ្ធិរាជ បានព្រះរាជអំណាចពេញសម្បូណ៌ បរិបាលសុខសប្បាយក្នុងកាយប្រទេស ល្បីឮសុសសាយទូទៅ ដល់ប្រទេសនានា ។

WAT KHEMARARATANARAM

# ឯកោ រាជា មច្ចុ នាម មហិទ្ធិកោ អហោសិ

សាធុសប្បុរសទាំងឡាយ !

ក្នុងទីមិនឆ្ងាយពីនគរកាយនោះ មានព្រះរាជាមួយព្រះអង្គទៀត ព្រះនាមព្រះបាទ មច្ចុរាជ ជាព្រះរាជាដ៏មានបរមឫទ្ធិ មានសន្ធានអាក្រក់ តែងព្រោចទៅព្រប សម្លាប់សព្វសត្វក្នុងត្រៃភព ទាំងពីមនុស្សលោកដល់ព្រហ្មលោក ឱ្យឋិតនៅក្នុងកណ្ដាប់ព្រះហស្តនៃព្រះអង្គ ។ ស្ដេចមានចតុរង្គសេនា ៤ កងពលធំ សុទ្ធតែជាមេទ័ពដ៏មានប្រតិពលក្នុងកលោបាយនិងយុទ្ធពិធីគ្រប់ចំពូក មានឥទ្ធិឫទ្ធិ៍ មេស្លាមហិមាអាចផ្ចាញ់បច្ចាមិត្រគ្រប់ទិសានុទិសឱ្យបរាជ័យ ឥតមី មាននរណាមួយក្នុងត្រៃលោកតស៊ូបានឡើយ ។

ចតុរង្គសេនា ៤ កងពលធំនោះ មានមេទ័ព ៤ នាក់គឺ

១_ នាយជាតិ ជាមេទ័ពមានសមត្ថភាពខាងស្ថាបនាវត្ថុធាតុផ្សេងៗ ដែលមិនទាន់កើត ឱ្យកើតឡើង

២_ នាយជរា ជាមេទ័ពមានសមត្ថភាពខាងធ្វើវត្ថុធាតុផ្សេងៗ ដែលខ្លាំងបង្កើតឡើងហើយ ឱ្យទ្រុឌទ្រោមទៅ

៣- ធាយព្យាធិ ជាមេទ័ពមានសមត្ថភាពអាចធ្វើឱ្យរាំងដែលមានកំលាំងរឹងប៉ឹង ឱ្យចុះញ្ញូលភាព ។

៤- ធាយមរណៈ ជាមេទ័ពមានសមត្ថភាពអាចសម្លាប់គ្នាតែបរូបម្នាក់ ។

មេទ័ពម្នាក់ ៗ មានបរិវារច្រើន តែងចេញចូលគាល់បម្រើរក្សាការពារព្រះអង្គព្រះបាទមច្ចុរាជជានិច្ចកាល. ព្រះបាទមច្ចុរាជតែងទ្រង់ ប្រើទៅសម្លាប់ពួកខ្មាំងទាំងពួងក្នុងត្រៃលោក ។

កិត្តិស័ព្ទព្រះបាទចិត្តរាជ បានល្បីរន្ទឺឮសាយទៅដល់ព្រះបាទមច្ចុរាជនោះថា មាននគរ ១ ឈ្មោះនគរកាយ ជាស្រុកនិច្ចសុខសប្បាយក្រៃពេក. ព្រះរាជា ជាអគ្គប្រមុខនគរកាយនោះ ព្រះនាមព្រះបាទចិត្តរាជ ជាបរមក្សត្រគ្រងសិរីសម្បត្តិសម្បូរណ៌ដោយព្រះរាជអំណាចមហិមា ។

កាលបើដំណឹងនោះ ឮសាយទៅដល់ព្រះសោតនៃព្រះបាទមច្ចុរាជ ៗ ក៏ទ្រង់វិតក្កយ៉ាងក្រៃលែង ខ្លាចក្រែងព្រះបាទចិត្តរាជកន្លងវិស័យនៃព្រះអង្គ ទ្រង់មានព្រះរាជបំណងនឹងប្រើមេទ័ព

ទាំង ៤ កងឲ្យទៅវាយបណ្ដើមយកនគរកាយនោះ ឲ្យនៅក្រោមអំណាចព្រះអង្គមួយរំពេច. តែស្ដេចទ្រង់ព្រះតម្រិះឃើញថា " ព្រះចាទចិត្តរាជ ជាមហាក្សត្រមានអានុភាពបរិមា មានសេនាទាហាននាហ្មឺនសព្វមុខមន្ត្រី ពុះករបរិបូណ៌ក្រៃពេក. បើអាត្មាអញលើកកងទ័ពទៅកាប់យកភ្លាម ៗ ឃើញជាពុំងាយបានឡើយ. ណើយកុំឲ្យខ្ចោះ ចាំអាត្មាអញប្រើចារទាហានទៅលបលួចយកដោយកលោបាយវិញ ពីអាត្មាអញត្រូវបញ្ជូនបេចាំពវមានសមត្ថភាព ឲ្យទៅក្លែងធ្វើជាខ្ញុំបំរើផ្ទាល់ព្រះចាទចិត្តរាជជាមុនសិន កាលបើចារទាហានអាត្មាអញទៅប្រតិបត្តិការចាំផុសម្រេចហើយ សឹមអាត្មាអញឲ្យលើកកងទ័ពទៅវាយយកជាក្រោយ. បើធ្វើឲ្យខ្ចោះប្រហែលជាបានងាយ " ។

កាលព្រះចាបត្តរាជទ្រង់ព្រះតម្រិះឃើញឧបាយដូច្នេះ ក៏ទ្រង់ព្រះបញ្ជាឲ្យហៅបេចាំពី ១ ឈ្មោះនាយជាតិចូលមកភ្លាម ។

លុះនាយជាតិចូលមកគាល់. ស្ដេចទ្រង់ត្រាស់ថា :

" ឯនាយជាតិ ! ចូរចាចចូលយកអាសារយើងក្នុងគ្រាឥឡូវនេះ. ចូរឯងទៅកាន់នគរកាយជាប្រញាប់ . កាលទៅ

បល់ ចូរឯងទៅអែបអបធ្វើខ្លួនឱ្យជាទីជឿជាក់ស្និទ្ធស្នាលជាមួយ និងសេវកាមាត្យ ព្រមទាំងមាតាបិតាវង្សាណាញាតិនៃព្រះបាទចិត្តរាជ. បើឯងបានជាទីស្និទ្ធស្នាលនឹងគេហើយ ចូរឯងចូលថ្វាយខ្លួនជាខ្ញុំគាល់បម្រើគេជានិច្ច និងធ្វើរាជការគេឱ្យល្អ ឱ្យគេទុកចិត្តរាប់អានស្រឡាញ់ផង ដើម្បីនឹងបានជាសេយ្យសឹកក្នុងស្រុកគេ. កាលធ្វើការបានសម្រេចហើយ ចូរឯងផ្ញើដំណឹងមកយើង ។

លុះត្រាស់ដូច្នោះ ក៏ទ្រង់បញ្ជូននាយជាតិឱ្យទៅកាន់នគរកាយ ឯនាយជាតិកាលបានទទួលព្រះរាជឱង្ការហើយ ក៏នាំបរិវារធ្វើដំណើរឆ្ពោះទៅកាន់នគរកាយនោះតាមព្រះរាជបញ្ជា

លុះនាយជាតិបានទៅដល់កាលណា ក៏ចូលទៅធ្វើជាមិត្តស្និទ្ធស្នាល ជាមួយនឹងនាហ្មឺនសព្វមុខមន្ត្រី ដោយសេចក្តីវៀវឆ្លាសរបស់ខ្លួន ហើយក៏ចូលទៅផ្គាប់ផ្គុនព្រះមាតា - បិតា អគ្គមហេសី និងព្រះញាតិវង្ស នៃព្រះបាទចិត្តរាជ. កាលឃើញថា វរជនទាំងនោះ គេស្រឡាញ់ពេញចិត្តអាណិតអាសូរខ្លួនហើយ ក៏ឱ្យគេនាំខ្លួនទៅថ្វាយព្រះមហាក្សត្រ ។ វរជនទាំងនោះ ក៏នាំនាយជាតិទៅ សូម្បីតែប៉ុនចុងសក់ក៏ទេ

ដោយវង្វេងតាមព្រះនាងអរិដ្ឋាទេវី ជាព្រះអគ្គមហេសី ពុំមានឱកាសចេញទៅទតព្រះនគរកាយបានឡើយ ។

ព្រះអធិប្ឌី ជាព្រះជីដូន កាលបានឃើញព្រះបាទចិន្តារាជនៅព្រងើយម្ល៉េះ ទើបចូលទៅថ្វាយព្រះពរតៀនម្ដងទៀតថា :

“ បពិត្រមហារាជ ដ៏ទ្រង់ព្រះករុណាភាព !

ហេតុម្ដេចបានជាព្រះអង្គគង់ស្ងៀមម្ល៉េះ ? មិនសមគួរទេព្រះអង្គ ! ឥឡូវព្រះនគរកាយរបស់ព្រះអង្គគ្រាំគ្រាហើយ សូមស្ដេចយាងទៅទតខ្លះផង ។

លុះព្រះជីដូនឃោសតើនបល់ពីរដង. ព្រះបាទចិន្តារាជទ្រាំគង់ស្ងៀមពុំបាន ក៏ទ្រង់ស្ដេចទៅទតបន្តិច ឃើញដូចពាក្យព្រះជីដូនរំលឹកមែន. តែគង់នៅស្ងៀមទៅវិញ ពុំបានគិតមើលព្រះនគរឡើយ ។ ទោសទាំងនេះមកតែពីទ្រង់វង្វេងដោយព្រះនាងអរិដ្ឋាទេវី ។

កាលនាយជាតិ និងជរា ជាមេទ័ពទាំង ២ នាក់ ឃើញអាការដូច្នោះ ក៏បញ្ជូនសារទៅថ្វាយ ព្រះបាទមធុរាជថា :

សូមព្រះតេជះពិគល់លើត្បូង
សូមព្រះរាជទានក្រោមបង្គំខ្ញុំព្រះករុណាជា
អម្ចាស់ជីវិត
សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

សូមទ្រង់មេត្តាប្រោស !

ឥឡូវព្រះបាទមិត្តរាជកំពុងប្រមាថ. សូមទ្រង់បញ្ជូនមេទ័ពទី ៣ ព្រមទាំងយោធាជាបរិវារទៅទៀត ដើម្បីប្រតិបត្តិការឱ្យឆាប់បានសម្រេចទាន់ព្រះរាជហឫទ័យផងទៅ ។

ហត្ថលេខា នាយជាតិ . ជរា

លុះព្រះបាទបត្តរាជ បានទ្រង់ជ្រាបព្រឹត្តិការណ៍នោះ ទើបទ្រង់ព្រះរាជបញ្ជាប្រើនាយព្យាធិជាមេទ័ពកណ្ដាលទី ៣ ព្រមទាំងបរិវារ ៩៦ នាក់ គឺឆន្នវុតិរោគឱ្យមកកាន់នគរកាយ ។ នាយព្យាធិព្រមទាំងបរិវារក៏នាំគ្នាទៅតាមព្រះរាជបញ្ជា . កាលទៅដល់ហើយនាយព្យាធិព្រមទាំងបរិវារ ៩៦ នាក់ បានញាំញីកំទេចទ្វារនគរនិងបន្ទាយតូចធំ ព្រមទាំងគ្រឿងប្រដាប់ផ្សេង ៗ ឱ្យរលំរលាយបាក់បែកគ្រប់អន្លើ . អ្នកនគរកើត

បលោបលរកចេញចូលពុំបាន ។ ធ្វើទាំងនេះ ដោយព្រោះតែប្លាប់យកព្រះបាទចិត្តរាជមួយមុខប៉ុណ្ណោះ ។

ឯព្រះពុទ្ធ ជាព្រះអ៊ីតុន កាលបានឃើញក៏ចូលទៅថ្វាយព្រះពរព្រះបាទចិត្តរាជថា :

“ បពិត្រមហារាជ ដ៏ទ្រង់គុណព្រះតេជានុភាព !

ព្រះអង្គមិនទាន់ជ្រាបទេឬ ? ឥឡូវព្រះធតរកាយនៃព្រះអង្គវិកលវិការហើយ ដោយនាយជាតិជាមេទ័ពទី ១ ដែលចូលមកនៅមុនបង្អស់គេគប់គិតក៏និតជាមួយ នាយជរាមេទ័ពទី ២ និង នាយព្យាធិមេទ័ពទី ៣ ព្រមទាំងពន្ធុរោគ ៩៦ នាក់ជាបរិវារនាំគ្នាធ្វើឱ្យវិករ. បើព្រះអង្គធ្វើព្រងើយកន្តើយ ព្រះធតរកាយមុខជាអន្តរាយពុំខានសូមទ្រង់ជ្រាប ” ។

ព្រះបាទចិត្តរាជបរមបពិត្រ កាលបានទ្រង់ព្រះសណ្ដាប់ឮឈ្មោះក៏រសាប់រសល់ក្នុងព្រះទ័យក្រៃពេក ទ្រង់ស្ដេចចេញទៅទតសព្វសព៌ាង្គព្រះធតរកាយ. លុះឃើញច្បាស់ក៏ទ្រង់សោយទុក្ខវេទនាទ្រង់ព្រះកន្សែងខ្សឹកខ្សួលជាខ្លាំង រកបុគ្គលណាមួយជួយយកអាសាក៏បាត់ព្យាធិសេនាជាខ្លាំងសន្ធឹកពុំបាន ដោយ

មហាជនទាំងពួងសឹងតែខ្លាចអំណាចព្យាធិសេនាទាំងអស់គ្នា ។

លុះនាយជាតិ _ ជរា _ ព្យាធិ ជាមេទ័ពទាំង ៣ នាក់ បានឃើញអាការដូច្នេះ ក៏បញ្ជូនសារទៅថ្វាយព្រះបាទ មច្ចុរាជថា :

សូមព្រះតេជៈបំកល់លើត្បូង
សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត
សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។
សូមទ្រង់ព្រះមេត្តាប្រោស !
ឥឡូវនេះ ព្រះបាទចិត្តរាជខ្សោយកម្លាំងណាស់ហើយ
សូមទ្រង់បញ្ជូនមេទ័ពទី ៤ ទៅទៀតជាប្រញាប់ ដើម្បី
ព្រួតគ្នាចាប់ឮព្រះបាទចិត្តរាជយកមកថ្វាយយ៉ាងរួសរាន់ ។

ហត្ថលេខា នាយជាតិ. ជរា. ព្យាធិ

កាលព្រះបាទមច្ចុរាជបានទ្រង់ជ្រាប ប្រព្រឹត្តិហេតុនោះ ក៏ទ្រង់ បញ្ជូនមេទ័ពទី ៤ ដ៏បំផុតឈ្មោះនាយមរណៈ ដ៏មានអនុភាពបរិមា ជាងមេទ័ពមុន ៗ អាចព្រោបព្រាប

បង្ហាបិត្រព្រល់ទិសតំបន់ ឱ្យវិនាសអន្តរាយកណ្តាលសមរភូមិ ។ សត្តធិករ ក្នុងព្រៃលោកសឹងកោតខ្លាចអំណាចរបស់គេនេះណាស់ គ្រាន់តែឮឈ្មោះថា មរណៈសេនាមកជិតដល់ក៏សឹងតែនាំគ្នារត់ប្រេកយកតែអាយុរៀងខ្លួន. តែទោះបីរួកណារត់ទៅពួនក្នុងទីណា ៗ ក្តី ក៏ពុំដែលរួចពីកណ្តាប់ដៃនាយមរណៈនោះបានឡើយ ។

ឯមេទ័ពទី ៤ ឈ្មោះនាយមរណៈកាលបានទទួលព្រះរាជបញ្ជាហើយ ក៏នាំបរិវារទៅកាន់នគរកាយ លុះចូលទៅដល់ទៅស្រុំគ្នានឹងមេទ័ពទាំង ៣ នាក់ដែលមកមុននោះ ហើយក៏រុករានទន្ទ្រានឫកដែនញាំញីបិទទ្វារទាំង ៩. នៃនគរកាយឱ្យងងឹតជុំវិញ ហើយចូលទៅបញ្ចាប់ក្នុងអង្គ ព្រះបាទចិត្តរាជបានព្រមទាំងនាហ្មឺនសព្វមុខមន្ត្រី និងអាណាប្រជាជនទាំងពួងគ្នានសល់ម្នាក់ នាំចេញចាកនគរកាយ ។

ឯនគរកាយនោះ កាលបើពុំមានបុគ្គលណាមួយនៅហើយក៏ទ្រុឌទ្រោមទៅ ។

នគរកាយ គឺរាងកាយយើង គេទាំងពួង. ព្រះបាទ

ចិត្តរាជ គឺចិត្តយើងគេទាំងពួង និមិត្តតែចិត្តពុំឋិតនៅក្នុង រាងកាយហើយ . រាងកាយក៏ពុំអាចទប់ទល់នៅបាន តែបម្លាស់ ប្ដូរភាពជារាងកាយស្អុយរលួយជាធម្មតា ដោយប្រការ ដូច្នេះ ។

សាធុសប្បុរសទាំងឡាយ !

កាលមេទ័ពទាំង ៤ នាក់ ព្រមទាំងបរិវារ ចាប់ ព្រះបាទចិត្តរាជបានហើយ ក៏នាំទៅកាន់សំណាក់ព្រះបាទ មច្ចុរាជ ។ ឯព្រះបាទមច្ចុរាជកាលឱ្យចាប់ព្រះបាទចិត្តរាជបាន មកហើយ នឹងយកទុកនៅជាខ្ញុំបម្រើក៏ទេ.' ត្រឡប់ជាបណ្ដេញ ទៅវិញថា " ចូរអ្នកឯងទៅតាមយថាភព្វខ្លួនចុះ ! ។

លំដាប់ពីនោះ ព្រះបាទចិត្តរាជក៏នាំបរិវារទៅរកទី លំនៅកសាងនគរកាយជាថ្មីដូចមុន ។

ឯព្រះបាទមច្ចុរាជជាស្ដេចកំបាប កាលបានជ្រាបថា ព្រះបាទចិត្តរាជកសាងនគរកាយជាថ្មី ក៏ទ្រង់ប្រើមេទ័ពទាំង ៤ ឱ្យទៅតាមបៀតបៀនចាប់ពួអង្គព្រះបាទចិត្តរាជ ឱ្យព្រាត់ចាក

នគរកាយជាថ្មី នោះទៀត និមិត្តថៃព្រះបាទចិត្តរាជកសាងនគរកាយវេលាណា ក៏ធ្វើឱ្យអន្តរាយវេលានោះរាល់គ្រា ពុំដែលខានឃ្លងណាឡើយ ។

ព្រះបាទចិត្តរាជ ក៏ទ្រង់សោយទុក្ខវេទនាគ្មានស្រាកស្រាន្ត ។

គ្រាមួយ ជាវេលាមានជោគវាសនាល្អ . ព្រះបាទចិត្តរាជក៏ទ្រង់ព្រះតម្រិះថា " អាត្មាអញធ្វើម្ដេចនឹងបានរួចពីកណ្ដាប់ដៃនៃមច្ចុរាជនេះបានអេះ ? ឱហ្ន៎ ! អាត្មាអញនឹងឱ្យទៅអារាធនាព្រះភិក្ខុជាព្រះជីតុន និងឥសីចូលមកប្រឹក្សាគ្នា ក្រែងលោកឃើញឧបាយយ៉ាងណាខ្លះ ? " ។ លុះទ្រង់ព្រះតម្រិះហើយក៏ទ្រង់ព្រះបញ្ជាប្រើមហាតលិក ២ នាក់គឺ ហ្លួនទេពនាជាមហាតលិកស្ដាំ. ហ្លួនបនស៊ិកវេរ ជាមហាតលិកឆ្វេងថា :

" នែបាទាំងឡាយ ! ចូរបាយកអាសាយើងទៅអារាធនាព្រះភិក្ខុជាព្រះជីតុនទាំង ៣ រូបគឺព្រះអនិច្ចំ_ទុក្ខំ_អនត្តា និងព្រះឥសីទាំង ៣ រូបគឺ ព្រះបីតិ _ ឆន្ទោ _ វិរិយោ ធូវបុរោហិតទាំង ៣ រូបគឺ ព្រះរាជគ្រូវិតក្កោ_វិចារោ អធិមោក្ខោហើយនិងអគ្គសេនាទាំង ១៩ នាក់មានឧកញ៉ាសទ្ធាជាដើម

ឱ្យមកកាន់សំណាក់យើងក្នុងខណៈនេះ " ។

មហាតល្លិកទាំងពីរនាក់ ក៏ម្នីម្នាទៅរកវរស្រេបណ៍និងវរជនទាំងនោះតាមព្រះរាជបញ្ជា ។ វរស្រេបណ៍ និងវរជនទាំងនោះ ក៏នាំគ្នាទៅកាន់ព្រះរាជសំណាក់តាមសេចក្តីអារាធនា-អញ្ជើញ. លុះទៅដល់ក៏ព្រះបាទចិត្តរាជត្រាស់ប្រឹក្សាការផែនដីថា :

" បពិត្រលោកអ្នកនិពុទ្ធទាំងឡាយ !

ខ្ញុំសូមប្រឹក្សា និងលោក សូមលោករកឧបាយ ដើម្បីឱ្យខ្ញុំរួចចាកកណ្តាប់ដៃនៃមន្ត្ររាជ " ។

ព្រះជីពុន ព្រមទាំងវរជនទាំងពួងដែលបានជួបជុំក្នុងមហាសន្និបាតនោះ ថ្វាយព្រះពរឡើងព្រមគ្នាថា :

" បពិត្រព្រះសម្មតិទេវរាជ !

ការប្រឹក្សាត្រានេះជាការធំបំណាស់ . ការនេះដែលនឹងសម្រេចបាច់ខាតទៅបាន លុះតែបានសម្តេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គ គឺព្រះសមាធិន្ទ្រិយ និងព្រះបញ្ញិន្ទ្រិយមកជាទីប្រឹក្សាផង. សូមព្រះអង្គឱ្យទៅអារាធនាសម្តេចមក " ។

ព្រះពោធិសត្វរាជបានទ្រង់ព្រះសណ្ដាប់ទីប្រជុំ ក៏ទ្រង់ត្រាស់ប្រើហ្លួងឯកត្ដា ជាមហាតព្វិកបាតចិត្តស្កត់ប្រាប់ថា :

- នែហ្លួងឯកត្ដា ! ចូរទៅអារាធនាសម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គមកជាប្រញាប់ - ។

ហ្លួងឯកត្ដា ក៏នាំព្រះរាជឱង្ការទៅថ្វាយទូលសម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គថា :

- បពិត្រសម្ដេចដ៏ទ្រង់នូវសីលធម៌បរិសុទ្ធ !

ព្រះពោធិសត្វរាជ ត្រាស់ប្រើទូលព្រះបង្គំជាខ្ញុំឲ្យមកអារាធនាសម្ដេចទាំង ២ ព្រះអង្គចូលទៅកាន់ព្រះនិវេសន៍ក្នុងខណៈនេះ - ។

សម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គ កាលបានទទួលនិមន្តហើយ ក៏ទ្រង់ស្លៀកស្បង់ក្រងចីពរស្ពាយបាត្រ ទ្រង់យាត្រាទៅតាមមាគ៌ាទាំង ៤ ជាលោកុត្តរមាគ៌ា តាមលំដាប់ គឺ សោតៈ សកទាគា អនាគា អរហត្ត ដែលជាមាគ៌ាអាចនាំព្រះពោធិសត្វរាជ ' ចេញផុតពីកណ្ដាប់ដៃនៃមាររាជដោយសួស្ដី ៣៦ ។

លុះសម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គនិមន្តដោយ

ថ្វើចូលទៅកាន់ព្រះរាជសំណាក់ គង់លើអាសនៈដ៏សមគួរហើយ ព្រះពោធិចិត្តរាជក៏ធ្វើសក្ការបូជាគោរពហើយក្រាបទូលពិតថេរបីគាថា :

" បពិត្រសម្ដេចទាំង ២ ព្រះអង្គ !

ញោមបានសេចក្ដីអផ្សុកខ្លាំងណាស់ បានជាឱ្យអារាធនាសម្ដេចជាម្ចាស់មក ដើម្បីទ្រង់ជួយដោះទុក្ខញោមក្នុងគ្រាឥឡូវនេះ ព្រោះមច្ចុរាជចេះតែមកបៀតបៀនញោម ដោយគេប្រើបេសកជនទាំង ៤ ព្រមទាំងបរិវារឱ្យមកធ្វើបាបញោម គ្រប់ពេលដែលញោមស្បានធរកាយ ពុំដែលខានពេលណា ព្រោះថ្នាំឱ្យញោមនៅក្នុងអំណាចគេ . បពិត្រសម្ដេចដ៏ចម្រើន ! ធ្វើដូចម្ដេចហ្ន៎ ឱ្យញោមបានរួចរំពីកណ្ដាប់ដៃសត្រូវនេះបាន ? " ។

សម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គ គឺព្រះសមាធិន្ទ្រិយ និងព្រះបញ្ញិន្ទ្រិយ លុះបានស្ដាប់ព្រះរាជឱង្ការហើយ ក៏ប្រឹក្សាជាមួយនឹង ព្រះជីពុធទាំង ៣ រូប គឺ ព្រះអនិច្ចំ-ទុក្ខំ-អនត្តា និងព្រះឥសីទាំង ៣ រូប គឺ ព្រះបីតិ-សទ្ធា-វីរិយោ ។

ន័យសេចក្ដីថា កាលសមាធិ និងបញ្ញាកើតឡើងក្នុងចិត្ត

ទើបពិតឃើញព្រះត្រៃលក្ខណ៍ . កាលព្រះត្រៃលក្ខណញ្ញាណ កើតមានឡើង តែងមានបីតិ ( អំណរ ) ផ្តួតផ្តាច់បង្គូទៅក្នុង អកុសលធម៌ទាំងពួង . មានឆន្ទៈ ( ស្រឡាញ់ ) កុសល កាត់អកុសលចោលបង់មិនត្រេកអរ និងមានវីរិយៈ ( ព្យាយាម ) ព្រាថ្នាឱ្យផុតចាកសង្សារវដ្ដ ។

សម្ដេចព្រះមហាសង្ឃរាជក៏ប្រឹក្សាធីងបុរោហិត ៣ រូប គឺរាជគ្រូវិតក្កោ_វិចារោ_អធិមោក្ខោតទៅទៀតថា " លោកណាយល់យ៉ាងណាខ្លះ ? " ។ រាជគ្រូទាំង ៣ រូប នឹករំពឹងទៅក៏ឃើញទោសរបស់បុគ្គលជាពួកអកុសល ហើយពិតថេរីកាថា " ទូលព្រះបង្គំជាខ្ញុំទាំងឡាយយល់តាមសម្ដេចទាំងអស់ " ។

កាលបើដូច្នោះ សម្ដេចមហាព្រះសង្ឃរាជទាំង ២ ព្រះអង្គ ក៏ប្រឹក្សាសួរទៅឧកញ៉ា ពញា ព្រះ ហ្លួង ឃុន ហ៊ុន និង មហាតព្វីកទាំងពួង មានឧកញ៉ាសទ្ធាជាដើមថា " លោកអ្នកទាំងអស់នេះ យល់ឃើញដូចម្ដេច ? " ។

វរជនទាំងនោះកាលប្រឹក្សាឃប់គ្នាគ្រប់ ក៏ពិតថេរីកាថា

ទោសទាំងនេះ មានតែពីពាបជនទាំង ១៤ ព្រះអង្គ

មានឃុនមោហោជាមើមជាព្រះញាតិវង្ស . ព្រះបាទមោហរាជជាព្រះបិតា . ព្រះនាងលោភទេវីជាព្រះមាតា និងព្រះនាងអវិជ្ជាទេវីជាព្រះអគ្គមហេសី បានស្ម័គ្រយកមេទ័ពទាំង ៤ នាក់របស់មច្ចុរាជ មានឆាយជាតិជាមើមឱ្យមកនៅក្នុងព្រះនគរកាយបានជាគេនាំគ្នាធ្វើព្រះនគរនេះឱ្យអន្តរាយអស់ ។

កាលទីប្រឹក្សាបានពិភាក្សាអស់កាលដ៏យូរ យល់ឃើញព្រមគ្នាហើយ ទើបយកសេចក្តីក្រាបបង្គំទូលព្រះបាទចិត្តរាជថា :

បពិត្រមហារាជ ដ៏ទ្រង់ធ្មព្រះរាជសម្ភារៈ !

ហេតុដែលនាំឱ្យខូចព្រះនគរកាយនេះ ទីប្រឹក្សាបានប្រឹក្សាឃើញមូលមតិគ្នាហើយថា មកពីព្រះអង្គទ្រង់ជឿពាក្យពួកពាលជនទាំង ១៤ អង្គ មានឃុនមោហោជាមើម ជាព្រះញាតិព្រះអង្គ .ជាសត្រូវក្នុងនាំសត្រូវក្រៅមកនៅក្នុងព្រះនគរ បានជាព្រះនគរកើតអន្តរាយអស់ច្រើនមួយទៀត មកពីព្រះបាទមោហោរាជជាព្រះបិតា ព្រះនាងលោភទេវីជាព្រះមាតា និងព្រះនាងអវិជ្ជាទេវីជាព្រះអគ្គមហេសី ដែលព្រះអង្គបានព្រមព្រៀងជាមួយនិងព្រះញាតិទាំង ១៤ អង្គទទួលយកមេទ័ពព្រះបាទមច្ចុរាជទុក

រុងព្រះនគរ ទើបពួកបច្ចាមិត្រតែងនាំគ្នាធ្វើព្រះនគរកាយរបស់ព្រះអង្គឱ្យអន្តរាយអស់ទេះ . រឿងនេះបើព្រះអង្គជឿស្តាប់យើងទាំងឡាយជាទីប្រឹក្សា សូមព្រះអង្គកំចាត់បង់ព្រះញាតិវង្សទាំង ១៤ អង្គ ព្រះមាតា_បិតា និងព្រះអគ្គមហេសីចេញ. ទើបបច្ចាមិត្រលែងកើតទៀតបាន . ហើយយើងទាំងពួងនឹងនាំព្រះអង្គទៅកាន់នគរកែវជាអមតមហានគរ ជាទីបរមសុខត្រាសចាកទុក្ខផុតពីកណ្តាប់ដៃ នៃមច្ចុរាជ តាមព្រះរាជបំណងបាន ។

កាលព្រះពាលចិត្តរាជបរមស្រុតបានទ្រង់ព្រះសណ្តាប់ហើយ . ដោយទ្រង់មានព្រះរាជបំណងចង់រួចពីកណ្តាប់ដៃនៃមច្ចុរាជ ទ្រង់ក៏ធ្វើតាមពាក្យទីប្រឹក្សាទាំងពួង មានសម្តេចព្រះមហាសង្ឃរាជជាដើម ទើបទ្រង់តាំងមហាតេជ្យិកម្នាក់ឈ្មោះហ៊ីនឯកគ្គតា និងអគ្គសេនាម្នាក់ឈ្មោះឧកញ៉ាចិត្តជិកតា ដែលមានចិត្តស្មោះត្រង់នឹងព្រះអង្គ ឱ្យជាមេក្រមជំនុំជំរះរឿងព្រះញាតិទាំងពួង ១៤ អង្គនូវព្រះមាតា_បិតា និងព្រះអគ្គមហេសីព្រមគ្នានៅទីចំពោះព្រះភក្ត្រព្រះអង្គ ។

ក្នុងសេចក្តីជំនុំជំរះ មេក្រមសួរថា :

នែព្រះបាទមហារាជ ! ព្រះនាងលោភទេវី ! ព្រះនាងអរិដ្ឋាទេវី ! លោកទាំងអស់អង្គសុទ្ធតែជាព្រះមាតាបិតា អគ្គមហេសីនៃព្រះរាជា ទាំងមុន ១៤ អង្គ ក៏សុទ្ធតែជាព្រះញាតិព្រះរាជាទាំងអស់ ព្រះរាជាទ្រង់ព្រោសព្រាណទាំងអស់លោកនាហ្នឹងព្រមគ្នា . ហេតុដូចម្តេចបានជាអស់លោកមិនពិគ្រោះព្រះអង្គដោយយុត្តិធម៌ បែរជាទៅក្រាបទូលណែនាំការមិនជាប្រយោជន៍ដល់ព្រះអង្គវិញ គឺនាំយកសត្វពីក្រៅឱ្យចូលមកនៅក្នុងព្រះនគរ ទាល់តែគេធ្វើបាបព្រះអង្គ ធ្វើឱ្យព្រះនគរព្រះអង្គឱ្យខូចអស់ដូច្នេះ ? . នែលោកអ្នកទាំងអស់ ! ចូរលោកអ្នកប្រាប់យើង ជាប្រញាប់ក្នុងពេលនេះ " ។

កាលនោះ ព្រះមាតាក្តី ព្រះបិតាក្តី ព្រះអគ្គមហេសីក្តី ព្រះញាតិទាំង ១៤ អង្គក្តី ពុំអាចឆ្លើយឱ្យការណ៍តែខ្លួនបានឡើយ សឹងតែទូលសារភាពថា " យើងទាំងពួងខុសមែន មានទោសច្រើនមែន . តាមតែទ្រង់ព្រះមេត្តាព្រោសដល់យើងខ្ញុំចុះ " ។

ព្រះបាទមិក្ករាជ កាលបានទ្រង់ព្រះសណ្តាប់ដូច្នោះ ទើប

ទ្រង់ព្រះរាជបញ្ជាប្រើឱកញ៉ាសុខា ជាអគ្គសេនាឱ្យពាំងទីកុណ្ឌ (១) ពិធីឡើង ។ គ្រានោះ ហេតុតែវាសនាបារមីព្រះបាទចិន្តារាជចាស់ក្លា និងដោយសារឫទ្ធិព្រះឥសីទាំង ៣ រូប គឺព្រះបិតិ - អន្ទោ - វិរិយោ លោកសូត្រសែកព្រះវេទមន្តឡើង. ព្រះខាន់ជ័យស្រីទាំង ៣ ក៏កើតឡើងកណ្តាលទីកុណ្ឌពិធីនោះ. ទើបព្រះឥសីទាំងឡាយថ្វាយព្រះពរថា :

" កាលនេះ ជាកាលគួរ ដែលព្រះអង្គទ្រង់យាងចូលទៅកាន់ទីកុណ្ឌពិធីហើយ សូមព្រះអង្គទាញយកព្រះខាន់ជ័យស្រីទាំង ៣ អំពីទីកុណ្ឌពិធីនោះចុះ " ។

ព្រះបាទចិន្តារាជព្រះអង្គលូកព្រះហស្ត ទៅទាញយកព្រះខាន់ជ័យស្រីទាំង ៣ អំពីគំនរភ្លើងនៃកុណ្ឌពិធី សូម្បីនឹងបានក្តៅព្រះហស្តបន្តិចបន្តួចក៏ទេ ។

ឯព្រះខាន់ជ័យស្រីទាំង ៣ នោះឈ្មោះ :

---

១ - ពិធីដែលគេធ្វើដោយជីករណ្តៅជម្រៅ ១ ចំអាម ៤ ធ្នាប់ ដុតភ្លើងបូជាយញ្ញតាមលទ្ធិព្រាហ្មណ៍ ។

១ - គចម្ពុំប្បហារ មានដំបងព្រាត់ អាចញាំញីសត្រូវបានដោយអង្គើ ។

២- វិជ្ជុធប្បហារ មានដងបាស អាចសម្លុតសម្លឹងសត្រូវឲ្យថ្នស្លុតស្ងៀមមិនឲ្យកម្រើកបាន

៣ - សមុទ្ទប្បហារ មានដងវិចិត្រដោយកែវ ៧ ប្រការអាចប្រហារសិរសារៈនៃសត្រូវទាំងឡាយ ឲ្យបាក់ឬចុះឆ្អោត កំបុតក ។

ព្រះពាទចិត្តរាជ . ទ្រង់ចាប់ព្រះខាន់ជ័យស្រីទាំងនោះ ព្រះរាជទានទៅអគ្គសេនាឈ្មោះឧកញ៉ាចិត្តបស្សទ្ធិ ដែលមានចិត្តថ្លាដូចកែវឲ្យជារាជពំណោង ដោយទ្រង់ព្រះរាជបញ្ជាថា ចូរអ្នកឯងសម្លាប់ព្រះបាទមោហរាជ ជាបិតាយើងដែលនាំឲ្យយើងវង្វេង. ព្រះនាងលោភទេវី ជាមាតាយើងដែលនាំឲ្យយើងលោភលន់ខ្លាំង. ព្រះនាងអវិជ្ជាទេវី ជាអគ្គមហេសីយើងដែលនាំឲ្យយើងងងឹតមុខជាប់ទៅតាមវា. ហើយចូរអ្នកឯងសម្លាប់ពួកពលផងទាំង ១៤ នាក់ ដែលជាព្រះញាតិវង្សយើង ហ្នឹង ពួកអស់នេះវាឲ្យសត្រូវខាងក្រៅចូលមកនៅក្នុងស្រុកយើង ឲ្យសត្រូវធ្វើឲ្យខូចព្រះនគរយើង យើងត្រូវតែសម្លាប់វាឲ្យ

អស់កុំឱ្យសល់ម្នាក់ ។

ឯឧកញ៉ាចិត្តបស្សទ្ធិ កាលទទួលព្រះរាជបញ្ជា ហើយក៏ប្រហារជីវិតជនអាពាលនោះ គ្មានសល់ម្នាក់ ដោយព្រះខាន់ឈ្មោះសមុទ្ទបហារ ។

អស់លោកអ្នកអានអ្នកស្តាប់រឿងនេះ សូមកុំយល់ថា ព្រះពាទបិត្តរាជមានរូបជាមនុស្សប្រើគេឱ្យសម្លាប់មាតាបិតា ... មានរូបជាមនុស្សឡើយ មិនមែនដូច្នោះទេ គឺចិត្តសម្លាប់ចេតសិកដែលទុកដូចជាមាតាបិតា ... ដោយរឿងនេះលោកលើកយកធម៌ ជាធម្មាធិដ្ឋានមកតែងជាបុគ្គលាធិដ្ឋានជាន័យប្រៀបធៀបដើម្បីឱ្យអ្នកមានប្រាជ្ញាតិចយល់បានងាយ ។ ឯព្រះពាទបិត្តរាជក៏គឺមួយចិត្តយើង . គេទាំងពួងទាំងឡាយ . នគរកាយក៏គឺរូបកាយយើងគេទាំងពួងនេះឯង . ទាំងព្រះមាតាព្រះបិតាព្រះអគ្គមហេសី និងព្រះញាតិ ១៤ អង្គក៏សុទ្ធតែជាអកុសលចេតសិកទាំងអស់ ។

អត្ថបទប្រៀបធៀប ដែលលោកលើកយកមកសំដែងនេះ ត្រូវគ្នានឹងអត្ថបទប្រៀបធៀប ដែលព្រះសម្ពុទ្ធទ្រង់សំដែងទុក

ក្នុងគម្ពីរខុទ្ទកនិកាយធម្មបទ ត្រង់បកិណ្ណកវគ្គថា :

មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ

បុគ្គលសម្លាប់តណ្ហាដូចមាតា . សម្លាប់អស្មិមានៈដូចបិតាសម្លាប់សស្សតទិដ្ឋិ ឧច្ឆេទទិដ្ឋិទាំងពីរ ដែលដូចខត្តិយរាជពីរព្រះអង្គ និងសម្លាប់អាយតនៈដូចដែន ព្រមទាំងនន្ទិរាគដូចស្មៀន តែងបានជាព្រាហ្មណ៍ ឥតមានទុក្ខ ទៅព្រះនិព្វាន ។

កាលឧកញ៉ាចិត្តបណ្ឌិត ប្រហារជីវិតជនទាំងនោះអស់ហើយ សម្ដេចព្រះមហាសង្ឃរាជ ២ ព្រះអង្គ . ព្រះជីគុន ៣ រូប . ព្រះឥសី ៣ រូប . បុរោហិត ៣ រូប . មហាតឡៀក ៧ នាក់ និងអគ្គសេនា ១៩ នាក់ ក៏ត្រាវឲ្យនិងសុំយាងព្រះបាទចិត្តរាជចេញចាកនគរកាយ ។

គ្រានោះ សម្ដេចព្រះសង្ឃរាជថ្វាយព្រះពរថា :

សូមព្រះអង្គយាងចុះមក អាត្មាភាពទាំងឡាយនឹងនាំព្រះអង្គទៅកាន់ព្រះនគរកែវ ជាស្រុកព្រះអរិយបុគ្គល អាត្មាភាពជាបន្ទុំស្ដេសក៍ នឹងនាំផ្លូវព្រះអង្គទៅតាមក្បួនឥឡូវនេះ " ។

ឯព្រះពោធិសត្វរាជ កាលបើស្ដេចព្រះមហាសព្វរាជទាំង ២ ព្រះអង្គ គឺព្រះសមាធិន្ទ្រិយ ព្រះបញ្ញិន្ទ្រិយ ពងណែនាំ ( គោលគឺសមាធិ និងបញ្ញាជាតកើតក្នុងចិត្តក៏ពិចារណាឃើញនូវសភាវធម៌ទាំងពួងតាមពិត ) ហើយ ទើបព្រះអង្គទ្រង់តាក់តែងព្រះកាយដោយគ្រឿងទិព្វរ័ត្នភូសា វិសេស សម្ភារកង ព្រះហស្ដរាក់ ស្អាប់ព្រះខ្លួន . ប្រកបទៅដោយកញ្ចប់ពិសេស គោលគឺព្រះពោធិបក្ខិយធម៌ ៣៧ ប្រការគឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ និងអដ្ឋង្គិកមគ្គ ៨ ជាគ្រឿងអលង្ការដ៏ល្អ ៗ រុងរឿង ហើយទ្រង់តាក់នូវព្រះចម្រង់គប់ប្រាបព្រះហស្ត ទាំង ១០ គោលគឺសិក្ខាបទ ១០ និងទ្រង់នូវព្រះមហាមកុដ គោលគឺសិក្ខាបទ ២២៧ និងទ្រង់នូវក្រោះពេជ្រសម្រាប់ព្រះតេជានុភាព គោលគឺព្រហ្មវិហារ ៤ ប្រការ គឺមេត្តា ករុណា មុទិតា

ឧបេក្ខា ហើយទ្រង់ជ្នះនូវព្រះខគ្គាវុធ គោលគឺសមុច្ឆេទបហាន ដែលអាចកាប់កាត់ផ្តាច់បង់សត្រូវទាំងពួង គោលគឺអកុសលទាំងអស់ផង ។ លុះទ្រង់គ្រឿងអលង្ការស្រេចហើយទើបទ្រង់យាងឡើងប្រថាប់លើព្រះធម្មរថ គោលគឺព្រះសទ្ធម្ម ៨៤.០០០ ព្រះធម្មក្ខន្ធហើយក៏ទ្រង់ពិសីទនាការលើរតនបល្ល័ង្ក ជាព្រះវិធាំងដ៏ប្រកបដោយកែវ ៩ ប្រការ គឺព្រះនវលោកុត្តរធម៌ ៩ គឺមគ្គ ៤ ផល ៤ និព្វាន ១ ។ ឯធម្មរថនោះសឹងទឹមដោយសេះសិន្ធពជាតិអាជានេយ្យ ៤ គឺព្រះចតុប្បារិសុទ្ធិសីលទាំង ៤ គឺបាតិមោក្ខសំវរសីល ឥន្ទ្រិយសំវរសីល អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ។ ធម្មអាជានេយ្យទាំង ៤ នេះនាំទាញនូវព្រះធម្មរថឱ្យអណ្តែតត្រសែតឡើងលើនភាល័យ. ហើយព្រះពោធិសត្វរាជបរមក្សត្រ ព្រះអង្គប្រកបដោយឥទ្ធិវិទ្ធិ ៤ ប្រការ គោលគឺឆន្ទិទ្ធិបាទ ( ឫទ្ធិសម្រេចដោយសេចក្តីព្រាថ្នា ) វីរិយិទ្ធិបាទ ( ឫទ្ធិសម្រេចដោយសេចក្តីព្យាយាម ). ចិត្តិទ្ធិបាទ ( ឫទ្ធិសម្រេចដោយបញ្ញា ). ហើយទ្រង់ពានព្រាស់ប៉ឹងនូវព្រះញាណទាំង ៤ ប្រការ គឺបុព្វេនិវាសញ្ញាណ វេសារជ្ជញ្ញាណ អនាវរណញ្ញាណ និង សព្វញ្ញុតញ្ញាណ ។

WAT KHEMARARATANARAM

វរជនទាំងឡាយ មានសម្តេចព្រះមហាសង្ឃរាជ ជាមគ្គទេសក៍ បាននាំព្រះបាទចិត្តរាជទៅតាមមាគ៌ាទាំង ៤ គឺ សោតា សកទាគា - អនាគា - អរហត្ត ជាផ្លូវលោកុត្តរៈ របស់ព្រះអរិយបុគ្គលទាំងពួងពីបុរាណ ។ ព្រះបាទចិត្តរាជក៏អណ្តែតត្រសែតលឿនលើវេហាស៍កណ្តាលហ្វូងយោធារេហ៍ពល បានទៅដល់ព្រះធាតុកែវជាស្រុកក្សេមក្សាន្តព្រាសចាកទុក្ខ ពោលគឺអមតមហានគរនិព្វាន ជាឋានបរមសុខប្រសើរផុតពីកណ្តាប់ដៃនៃមច្ចុរាជពីសេចក្តីស្លាប់ មច្ចុរាជមិនអាចតាមបំផ្លាញព្រះអង្គដូចពីមុនបាន ដោយហេតុព្រះអង្គយាងចូលសឹងទៅក្នុងព្រះនគរកែវ គឺព្រះនិព្វានដ៏មានកំពែងកែវ ៧ (១) ជាន់ជិតជុំបាំងមាំមួនក្រៃពេក ជាព្រះនគរដ៏ព្រាសចាកទុក្ខទាំង ៤ គប. គឺជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខដែលមិនដល់យល់ឃើញ ឡើយ ។

---

១ សត្តពោជ្ឈង្គទាំង ៧ គឺសតិសម្ពោជ្ឈង្គ. ធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ. បីតិសម្ពោជ្ឈង្គ. បស្សទ្ធិសម្ពោជ្ឈង្គ. សមាធិសម្ពោជ្ឈង្គ. ឧបេក្ខាសម្ពោជ្ឈង្គ ទុកជាកំពែងកែវ ៧ ជាន់ ។

ព្រះបាទចិត្តរាជបរមបវិត្រ ព្រះអង្គបានគង់នៅជាបរមសុខ

ក្នុងបាននិព្វាន ដូចបានពណ៌នាមក ។

ធម្មកថានេះ ពណ៌នាតាមលំអានបរមត្ថធម៌ ដែលព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់សំដែងអំពីកាយ និងចិត្ត ជាគ្រឿងធម៌ទៀបត្រៃលោក ដើម្បីពន្យល់សាធុជនដែលបានអានបានស្តាប់ឱ្យយល់ច្បាស់ទោសនៃជាតិ ជរា ព្យាធិ មរណៈ ដែលនាំសត្វឱ្យហែលវិលវល់ក្តុងក្តុងនៅក្នុងសមុទ្រនៃវដ្តសង្សារ ។

សាធុជនដែលបានអាន បានស្តាប់នូវសព្ទព្រះធម៌នេះ ដើម្បីកុំ កត់សំគាល់ចាំឱ្យជាក់ច្បាស់គ្រប់ន័យ ន័យត្រង់ណាដែលធម្មកថានេះពោលសង្ខេប គឺគ្រាន់តែរាប់ឈ្មោះពុំបានប្រែ ពុំបានអធិប្បាយ ឬអធិប្បាយដោយខ្លី ៗ បើស្តាប់សេចក្តីពុំបាន គប្បីសាកសួរប្រឹក្សាអស់បណ្ឌិតបរមត្ថសាស្ត្រ ដែលជ្រៀវជ្រាសក្នុងបរមត្ថធម៌ឱ្យលោកពន្យល់តទៅ ។

សូមសេចក្តីសុខ សេចក្តីចម្រើន កើតមាន
ដល់លោកអ្នកអាន អ្នកស្តាប់ទាំងឡាយ សព្វ ៗ កាល !

ចាប - ពិន

ចប់